**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យសន្តីថេរេសា នៃក្រុងឡេស្សឺនៅកាម៉ែល**
**ថ្ងៃទី០១ តុលា ២០១៧**

អត្ថបទទី១៖ អគ ១៨,២៥-២៨
អត្ថបទទី២៖ ភីល ២,១-១១
ដំណឹងល្អ៖ មថ ២១,២៨-៣២

បងប្អូនជាទីស្រឡាញ់!

នៅទីក្រុងឡេស្សឺ មានកម្មវិធីពេញតាំងពីម្សិលមិញរហូតដល់អាទិត្យក្រោយ ដើម្បីឲ្យគ្រីស្តបរិស័ទជិតស្និទ្ធជាមួយសន្តីតេរេសា។ ថ្ងៃនេះជាថ្ងៃអស្ចារ្យសម្រាប់យើង ដោយសារគេមិនអញ្ជើញកាឌីណាល់មកពីអឺរ៉ុប គឺកាឌីណាល់មកពីអាស៊ីដែលកំពុងថ្វាយអភិបូជានៅឡេស្សឺ ជា ឱកាសមួយដើម្បីយល់ថាសន្តីតេរេសាមកដើម្បីជួយឲ្យគ្រីស្តបរិស័ទយើងទាំងអស់ទៅគោះទ្វារនៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក ដើម្បីដើរតាមមាគ៌ាយ៉ាងពិសេសដែលសន្តីតេរេសាបានរៀបចំឲ្យ។ គម្ពីរដែលយើងបានស្តាប់ថ្ងៃនេះ ជាគម្ពីរមួយដែលណែនាំឲ្យយើងយល់អំពីជីវិតរបស់យើងខ្លះៗដែរ ប៉ុន្មានដងប៉ុន្មានសារយើងបានខិតខំឆ្លើយទៅព្រះជាម្ចាស់ថា យើងបានខិតខំធ្វើនេះធ្វើនោះតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ តាមព្រះបន្ទូលរបស់ព្រះអង្គ ប៉ុន្តែក្រោយមកយើងមិនធ្វើអ្វីសោះយើងទុកចោលដោយសារយើងរវល់ធ្វើអ្វីផ្សេង ពេលនោះយើងដូចជាកូនពៅ។ ប៉ុន្តែថ្ងៃនេះ ព្រះយេស៊ូចង់ឲ្យយើងចាប់អារម្មណ៍អំពីកូនច្បងដលពីដំបូងគាត់បានបដិសេធ ប៉ុន្តែក្រោយមកគាត់បានដូរចិត្តគំនិតនឹងបានធ្វើតាមអ្វីដែលឪពុកគាត់បានសុំឲ្យគាត់ធ្វើ។ នៅពេលនោះព្រះយេស៊ូបានលើកអំពីស្ត្រីពេស្យា អំពីអ្នកទាពន្ធ ដែលមនុស្សលោកយល់ថាជាមនុស្សខ្វះសីលធម៌ជាមនុស្សមានបាប គេបានដើរផ្លូវខុស ប៉ុន្តែគេបានយកចិត្តទុកដាក់ដើម្បីកែប្រែចិត្តគំនិតនៅក្នុងជីវិតរបស់គេ។ ដូចព្រះយេស៊ូបានបង្ហាយ៉ាងច្រើនដូចជាលោកសាខេ លោកឡេវីលោកម៉ាថាយ សន្តីម៉ារីម៉ាដាឡា និងមានប៉ុន្មាននាក់ទៀតដែលយើងបានលឺនៅក្នុងព្រះគម្ពីរ គេបានយកចិត្តទុកដាក់ដើម្បីទទួលជីវិតថ្មី។ អ្នកដែលកាន់វិន័យ ដូចជាពួកបូជាចារ្យពួកធម្មជាចារ្យ ពួកនាយកបូជាចារ្យគេមិនចេះមើលគេ ដោយសារគេយល់ថាគេរស់នៅក្នុងរបៀបត្រឹមត្រូវ គេភ្លេចមើលខ្លួនឯង។ គេភ្លេចស្រាវជ្រាវអំពីជីវិតរបស់គេ ដើម្បីគេនឹកឃើញអ្វីដែលគេបានធ្វើខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ថ្ងៃនេះដែលយើងគោរពសន្តីតេរេសានៃព្រះកុមារយេស៊ូ ជា ឱកាសមួយដើម្បីនឹកឃើញអ្វីដែលសន្តីតេរេសាបានរៀបចំឲ្យយើង។ មុនគេបង្អស់សន្តីតេរេសាបានត្រាស់ហៅយើងឲ្យរស់នៅជាសសន្តសន្តី ជីវិតរបស់គាត់គាត់ធ្វើយ៉ាងណាដើម្បីក្លាយជាសន្តសន្តី។ នៅពេលសន្តីតេរេសាមានអាយុ៩ឆ្នាំ គាត់រឿងអំពីហប្រាតាគាត់ភ្ញាក់ហើយគាត់និយាយថាខ្ញុំចង់ធ្វើជាសន្តីមួយយ៉ាងពិសេស ខ្ញុំចង់ដើរតាមព្រះជាម្ចាស់នៅក្នុងរបៀបមួយយ៉ាងពិសេស។ សន្តីតេរេសា បានណែនាំឲ្យជីវិតដ៏វិសុទ្ធដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទោះបីយើងឆ្លើយថាមិនធ្វើទេតែក្រោយមកយើងធ្វើ ទុកឲ្យយើងមានពេលវេលាដើម្បីកែប្រែ គឺជាជីវិតសម្រាប់មនុស្សទាំងអស់ អ្នកណាក៏ដោយក៏អាចក្លាយជាសន្តសន្តី។ តាមពិតឥតមានសន្តសន្តីពិសេស ព្រោះថានៅពេលយើងទៅជាសន្តសន្តីមានន័យថាអស់មួយជីវិតរបស់យើងយើងបានធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូច្នេះព្រះជាម្ចាស់មិនទន្ទឹងរងចាំស្នាដៃមួយយ៉ាងអស្ចារ្យ ឬស្នាដៃមួយដែលណែនាំឲ្យមានការកោតសរសើរពីលោកីយ៍ ប៉ុន្តែព្រះជាម្ចាស់ទន្ទឹងរងចាំស្នាដៃមួយគត់ គឺយើងធ្វើដូចម្តេចដើម្បីឲ្យចិត្តគំនិតរបស់យើងយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ។ យើងមើលឪពុកម្តាយរបស់សន្តីតេរេសាគ្មានការអស្ចារ្យប៉ុន្មានទេ គាត់បានចិញ្ចឹមកូនរបស់គាត់នឹងណែនាំឲ្យស្គាល់ព្រះជាម្ចាស់ គាត់បានយកចិត្តទុកដាក់ធ្វើការដើម្បីចិញ្ចឹមជីវិតរបស់គាត់ គាត់បានយកចិត្តទុកដាក់អធិដ្ឋានដើម្បីឲ្យគ្រួសាររបស់គាត់មានសេចក្តីសុខ គាត់បានអនុញ្ញាតឲ្យកូនគាត់ចូលនៅក្នុងអារាមដោយមិនបដិសេធតែប៉ណ្ណឹង។ គាត់មិនបានធ្វើឲ្យមានស្នាដៃពិសេសណាមួយទេ សន្តីតេរេសាក៏ដូចគ្នាដែរ ពេលសន្តីតេរេសាស្លាប់គ្មានអ្នកណាដែលស្គាល់គាត់សោះ គាត់គ្រាន់តែជាបងស្រីសម្ងាត់ម្នាក់នៅក្នុងអារាមមួយតែប៉ុណ្ណឹង។ នៅពេលគេរៀបចំឯកសារដើម្បីឲ្យបងស្រីតេរេសសាធ្វើជាសន្តីគេទៅនិយាយជាមួយបងស្រីប្រធាន ដែលឈ្មោះម៉ារីឌីប៉ុងសាល នៅពេលនោះគាត់សើចប្រសិនបើយើងឲ្យតេរេសាធ្វើជាសន្តី យើងមានយុវនារីច្រើនទៅជាសន្តីដែរ។ ដោយសារ មានបងបទស្រីច្រើនឥតបានគាំទ្រថាតេរេសាមិនបានធ្វើអ្វីពិសេសទេ ប៉ុន្តែក្រោយមកសន្តីតេរេសាទៅជាគំរូមួយសម្រាប់គ្រីស្តបរិស័ទទាំងអស់ គំរូដោយសារគាត់បានបើកផ្លូវយ៉ាងតូចមួយ ដែលណែនាំឲ្យយើងយល់ថាធ្វើដូចម្តេចដើម្បីឲ្យយើងទុកជីវិតរបស់យើងនៅក្នុងដៃរបស់ព្រះយេស៊ូ។ ដោយសារ នៅពេលគាត់សម្រេចចិត្តយ៉ាងច្បាស់លាស់ធ្វើជាសន្តីម្នាក់នៅពេលនោះគាត់យកកម្លាំងផ្ទាល់ខ្លួន គាត់និយាយច្រើនដងធ្វើជាសន្តីត្រូវការតស៊ូយកចិត្តទុកដាក់ ដូចជាធ្វើសង្គ្រាមដើម្បីរស់នៅក្នុង

របៀបសន្តីម្នាក់។ ដំបូងគាត់យកកម្លាំងផ្ទាល់ខ្លួន ដោយយកចិត្តទុកដាក់ស្រឡាញ់គេផ្ទាល់ខ្លួន ប៉ុន្តែបន្តិចម្តងៗនៅពេលគាត់បង្កើតផ្លូវដ៏តូចរបស់គាត់ គាត់យល់ថាដោយកម្លាំងខ្ញុំខ្ញុំធ្វើមិនបានទេ ដោយសមត្ថភាពខ្ញុំផ្ទាល់ខ្លួនខ្ញុំធ្វើមិនបានទេ ទោះបីខ្ញុំមានគោលបំណងធ្វើជាសន្តីម្នាក់ពិតមែន ប៉ុន្តែខ្ញុំជាអ្នកណាដើម្បីធ្វើកើត។ ដូច្នេះនៅពេលនោះគាត់យល់ថាមានតែព្រះយេស៊ូដែលអាចជួយគាត់ធ្វើជាសន្តីម្នាក់បាន បន្តិចម្តងៗគាត់បានលះបង់ចោលដើម្បីទុកឲ្យព្រះយេស៊ូកែប្រែចិត្តគំនិតរបស់គាត់ដោយរសស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នៅពេលនោះ គាត់បានបង្កើតផ្លូវដ៏តូចតាចមួយដែលណែនាំឲ្យចិត្តគំនិតរបស់គាត់ទៅជាចិត្តគំនិតដូចកូនក្មេងម្នាក់ ដែលទីពឹងលព្រះបិតា ដែលទីពឹងលើព្រះជាម្ចាស់ ដូចកូនក្មេងមានតែឪពុកម្តាយដែលចិញ្ចឹម ដែលជួយឲ្យចេះដើរ ចេះនិយាយ ចេះអ្វីៗទាំងអស់។ ដូច្នេះគាត់យល់ថា ប្រសិនបើខ្ញុំចង់ឲ្យព្រះជាម្ចាស់ទទួលខ្ញុំ ខ្ញុំត្រូវការធ្វើដូចកូនក្មេងម្នាក់ ដើម្បីលះបង់ចោលអ្វីៗទាំងអស់ដោយធ្វើតាមព្រះជាម្ចាស់ ដើម្បីទីពឹងលើព្រះហឫទ័យព្រះជាម្ចាស់ដើម្បីរស់នៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់។ ប៉ុន្តែនេះមិនណែនាំឲ្យគាត់យល់ថាឥលូវនេះស្រួលហើយ ខ្ញុំជ្រើសរើសផ្លូវតូចមួយនឹងទុកឲ្យព្រះជាម្ចាស់ធ្វើឲ្យហើយខ្ញុំគ្រាន់តែទន្ទឹងរងចាំឲ្យព្រះជាម្ចាស់ទទួលខ្ញុំដោយមិនបានធ្វើអ្វីសោះ។ ផ្ទុយទៅវិញនៅពេលនោះសន្តីតេរេសាយល់ថា ខ្ញុំធ្វើដូចម្តេចដើម្បីរីកចម្រើននៅក្នុងជីវិតរបស់ខ្ញុំជាគ្រីស្តបរិស័ទម្នាក់ ជាកូនរបស់ព្រះជាម្ចាស់ម្នាក់ ដោយយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងខ្លាំងទៅៗ យកចិត្តទុកដាក់អធិដ្ឋានយ៉ាងខ្លាំងទៅៗ ដើម្បីឲ្យជីវិតខាងក្នុងអាចរីកចម្រើនបាន។ យើងដឹងថាប៉ុន្មានឆ្នាំចុងក្រោយនៃជីវិតរបស់គាត់ គាត់បានចូលនៅក្នុងភាពងងឹតដោយសារជំងឺ គាត់ពិបានធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយសារឥតមានអ្វីដែលជាសេចក្តីស្រឡាញ់ ដែលណែនាំឲ្យកក់ក្តៅនៅក្នុងជីវិតរបស់គាត់។ ប៉ុន្តែបន្តិចម្តងៗគាត់បានអនុវត្តតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដោយស្រឡាញ់ព្រះជាម្ចាស់ ធ្វើជាធ្លុងតែមួយជាមួយព្រះជាម្ចាស់តែម្តងនៅក្នុងជីវិតរបស់គាត់។ ដោយសារតាមពិតគាត់នៅកាម៉ែលតែ៩ឆ្នាំ ប៉ុន្តែក្នុងរយៈពេលហ្នឹងគាត់ធ្វើយ៉ាងណាដើម្បីឲ្យជាប់ជាមួយព្រះយេស៊ូ ជាមួយព្រះជាម្ចាស់យ៉ាងខ្លាំងទៅៗ ដែលគាត់បង្ហាញនៅក្នុងជីវិតប្រចាំថ្ងៃរបស់គាត់ ដោយយកចិត្តទុកដាក់រស់នៅជាបងស្រីធម្មតា ប៉ុន្តែជាបងស្រីដែលរស់នៅក្នុងសេចក្តីស្រឡាញ់ បម្រើបងស្រីឯទៀតៗ យកចិត្តទុកដាក់ជាមួយបងស្រីឯទៀតៗ។ មានថ្ងៃមួយ មានបងស្រីម្នាក់សុំធ្វើការងារមួយដែលគាត់ត្រូវតែធ្វើ ហើយគាត់ទុកឲ្យបងស្រី

នោះធ្វើ នៅពេលនោះគេរិះគន់គាត់ថាខ្ជិលណាស់សុខចិត្តទុកឲ្យបងស្រីចាស់ធ្វើ ប៉ុន្តែនៅក្នុងចិត្តគាត់ គាត់ចង់បង្ហាញធម៌មេត្តាករុណាដោយសារបងស្រីម្នាក់នោះគាត់ចង់ធ្វើ គាត់សុំធ្វើដើម្បីឲ្យគាត់ជាប់ជាមួយព្រះជាម្ចាស់ថែមទៀត។ តាមពិតជីវិតរបស់គាត់រីកចម្រើនខ្លាំងបំផុតដោយសារ គាត់ទុកចិត្តលើព្រះហឫទ័យមេត្តាករុណា និងជាពិសេសលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ គាត់យល់ថា ទោះបីគាត់មានបាបច្រើន ទោះបីគាត់មិនទាន់បរិសុទ្ធដល់កំពូល ប៉ុន្តែពញរះជាម្ចាស់លើកលែងទោសឲ្យគាត់។

យេរ៉ូម ជាបូជាចារ្យម្នាក់ដែលគាត់ណែនាំខាងផ្លូវវិញ្ញាណ ដោយសរសេរសំបុត្រប៉ុន្មានដង ដោយសារគាត់នៅអាប្រ៊ិច គាត់បានសួរថារអតីតជីវិតរបស់ខ្ញុំមានបាបច្រើន តើធ្វើយ៉ាងណាដើម្បីរួមជាមួយព្រះជាម្ចាស់? សន្តីតេរេសាបានផ្ញើទៅគាត់ថា កុំព្រួយបារម្ភប្រសិនបើបានធ្វើអំពើបាបទៅលើព្រះជាម្ចាស់ និងប្រសិនបើនៅជិតនឹងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់អាចមានជីវិតថ្មីបាន ដោយសារព្រះជាម្ចាស់រំដោះបាបរបស់យើងទាំងអស់ ដើម្បីឲ្យមានជីវិតថ្មីនិងដើម្បីឲ្យរីកចម្រើន។ នេះផ្ទុយនឹងអ្វីដែលយើងឃើញនៅថ្ងៃនេះជាមួយនាយកបូជាចារ្យ និងព្រឹទ្ធាចារ្យ ជាមូលហេតុព្រះយេស៊ូបានស្តីឲ្យគេដោយសារគេមិនចេះទទួលស្គាល់អំពីមនុស្សដែលជាមនុស្សទុច្ចរិត ប៉ុន្តែជាមនុស្សដែលចង់កែប្រែចិត្តគំនិតដើម្បីទទួលជីវិតថ្មី។ ទោះបីសព្វថ្ងៃ នៅក្នុងព្រះសហគមន៍យើងមានគ្រីស្តបរិស័ទប៉ុន្មាននាក់ ដែលមិនចេះទទួលមនុស្សដែលមានអតីតកាលមិនសូវល្អប៉ុន្តែគេចង់មានជីវិតថ្មី និងព្រះជាម្ចាស់ទទួលគេ។

ដូច្នេះថ្ងៃនេះ យើងអរព្រះគុណព្រះអង្គដែលប្រទានសន្តីតេរេសា ដើម្បីណែនាំឲ្យយើងធ្វើដំណើរនៅក្នុងជីវិតសុច្ចរិត និងនៅក្នុងជីវិតដ៏វិសុទ្ធរួមជាមួយព្រះជាម្ចាស់ ដើម្បីរស់នៅក្នុងសេចក្តីសុខសាន្តនិងដើម្បីណែនាំឲ្យព្រះសហគមន៍រីកចម្រើន ដោយសារព្រះសហគមន៍ជាព្រះសហគមន៍ដ៏វិសុទ្ធ ប៉ុន្តែធ្វើដោយមនុស្សដែលមិនមែនដ៏វិសុទ្ធដល់កំពូល ប៉ុន្តែយើងដឹងថាប្រសិនបើយើងយកចិត្តទុកដាក់កែប្រែចិត្តគំនិត យើងអាចទទួលជីវិតថ្មីនិងរស់នៅតាមរបៀបព្រះជាម្ចាស់តែម្តង ដោយយកចិត្តទុកដាក់នឹងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្ត។ ដូច្នេះយើងអធិដ្ឋានសម្រាប់ព្រះសហគមន៍របស់យើង សម្រាប់គ្រីស្តបរិស័ទ សម្រាប់បងប្អូនឯទៀតៗ ជាពិសេសសម្រាប់បងប្អូនដែលកំពុងស្វែងយល់ ដើម្បីរកឃើញផ្លូវមួយយ៉ាងពិសេសរួមជាមួយព្រះជាម្ចាស់ ដោយយល់ថាពិតមែន យើងជាគ្រីស្ត

បរិស័ទទាំងអស់ យើងមានគោលដៅតែមួយ គឺធ្វើយ៉ាងណាឲ្យយើងភ្ជាប់ជាមួយព្រះជាម្ចាស់និងព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន៕